# តើមានកើតរឿងអ្វី បើអ្នកត្រូវគេចាប់ខ្លួន



ប្រព័ន្ធយុត្តិធម៌ នៅក្នុងសហរដ្ឋអាមេរិក ខុសប្លែកពីប្រទេស ដទៃទៀត។ ខាងក្រោមគឺជាសំនួរខ្លះៗ នឹងចម្លើយខ្លះៗ ឲ្យជាយោបល់ សំរាប់ឲ្យអ្នកយល់ច្បាប់ នៅក្នុងសហរដ្ឋ និងក្នុងសង្កាត់ សាន់តាក្លារ៉ា។

## ក្រសួងប្រតិបត្តិច្បាប់ នៅសង្កាត់សាន់តាក្លារ៉ា គឺជាក្រសួងអ្វី ?

មានក្រសួងប៉ូលិសក្រុង១០ ដែលបានធ្វើការបំរើក្នុងទាំងអស់ក្នុង សង្កាត់សាន់តាក្លារ៉ា។ គេបានធ្វើការឃាមល្បាតព្រំដែនរបស់ក្រុង។ កន្លែងដែលគ្មានជាប់ ជាមួយទីក្រុងណា ត្រូវបានទទួលការឃាម ល្បាត ពីប៉ូលិសតំបន់ (Sheriffs office of Santa Clara )។ The Department of Corrections មើលការត្រួតត្រាមន្ទីរឃុំឃាំង។ California Highway Patrol CHIP ត្រួតត្រាលើផ្លូវ Highway។ ក្រសួងអន្តោប្រវេសន៏ INS ( the Immigration and Naturalization Servises ) មានតាំងនៅទីក្រុងសាន់ហ្វូស្សេ ដែល មានក្រសួងអនុវត្តិច្បាប់ និងកន្លែងឃុំឃាំងផង។

## តើខ្ញុំគួរតែធ្វើយ៉ាងណា បើខ្ញុំជាជនរងគ្រោះដោយ បទឧក្រិដ្ឋ ឬជាសាក្សីអំពើឧក្រិដ្ឋ ?

អ្នកត្រូវតែរាយការណ៏ ដល់ប៉ូលិសដោយទូរស័ព្ទលេខ ៩១១។

## ការចាប់ខ្លួនជាអ្វីទៅ?

កាលណាអ្នកបានត្រូវគេចាប់ចង អ្នកគ្មានសេរីភាព នឹងចាកចេញពី ទីកើតហេតុបានទេ (taken in to custody)។ បទឧក្រិដ្ឋ បានត្រូវ ចាប់ផ្តើមធ្វើឡើង នៅពេលដែលអ្នកនោះ បានគេត្រូវចាប់ចង ដោយប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលបានចោតឡើង។ មនុស្សដែលធ្វើ បទឧក្រិដ្ឋអាចគេចាប់បាន ដោយអ្នកមានសញ្ជាតិពលរដ្ឋពេញលេញ ដោយក្រសួងមានសមត្ថកិច្ច ឬដោយសារសំបុត្របញ្ជា ឲ្យចាប់ត្រូវ បានចេញឲ្យ។ ដើម្បីឲ្យសំបុត្របញ្ជាឲ្យចាប់នោះ អាចគ្មានន័យបាន គេត្រូវតែ មានមូលហេតុដោយការស្មានប្រហែល "probable cause."។

## អ្វីទៅជា "Probable Cause" ?

Probable Cause មានអត្ថន័យថា ជាផោសតាងដែលគាំទ្រអ្នក យកការណ៏ ដែលមានជំនឿថា ល្មមសមគួរឲ្យជឿ អំពីអំពើទុច្ចរិត ដែលបានប្រព្រឹត្តឡើង។

## តើខ្ញុំមានសិទ្ធិអ្វីខ្លះ បើសិនជាគេចាប់ខ្ញុំ ទៅស្ថានីយ ប៉ូលិស?

ទោះបីអ្នកជាប្រជាពលរដ្ឋ របស់ប្រទេស ឬមិនមែនក៏ដោយ អ្នកត្រូវតែមានសិទ្ធិដែរ ទោះបីត្រូវគេដាក់ខ្នោះក៏ដោយ។ មុននិងប៉ូលីស សួរចម្លើយអ្នក គេត្រូវប្រាប់អ្នកថា :

- អ្នកមានសិទ្ធិនៅស្ងៀមស្ងាត់ ដោយពុំបាច់ឆ្លើយអ្វីឡើយ។
- ពាក្យសំដីដែលអ្នកបាននិយាយ អាចប្រើប្រឆាំងនឹងខ្លួន ឯងវិញបាន។
- អ្នកមានសិទ្ធិរកមេធាវីឲ្យជួយបាន ក្នុងពេលគេចោទសួរ។
- បើអ្នក គ្មានប្រាក់ជួលមេធាវីទេនោះ គេអាចចាត់តាំងម្នាក់ ឲ្យបាន។

បើគេបញ្ចេញសិទ្ធិខ្លួនថា ត្រូវតែរកមេធាវីនោះ ភ្នាក់ងារប៉ូលិសមិន អាចបន្តសួរចម្លើយបានទេ។ បើភ្នាក់ងារនៅតែបន្តសាកសួរចម្លើយ ឥតឈប់ឈរ ជាមូលហេតុសំខាន់ណាស់ ដើម្បីទាមទាររកមេធាវី។ ប៉ុន្តែភាគច្រើនភ្នាក់ងារ នឹងឈប់សួរដេញដោលរហូត ដល់មាន មេធាវិ។

## ចុះបើខ្ញុំត្រូវឡើងតុលាការ តើត្រូវធ្វើដូចម្តេច ?

បន្ទាប់ពីគេចាប់ខ្លួនអ្នកហើយនោះ អ្នកនឹងត្រូវតុលាការចោទ។ ក្នុងពេលនោះ អ្នកត្រូវបង្ហាញខ្លួនដល់ចៅក្រម ដែលលោកនឹងលើក យករឿងដែលចោទប្រឆាំងអ្នកឲ្យអ្នកស្តាប់។ នៅពេលនោះអ្នកអាចទទួល ជាជនមានកំហុស ឬមិនមានកំហុស ឬទទួលមិនតវ៉ា។ បើសិនជាអ្នកឆ្លើយថា មិនទទួលទោសទេ បន្ទាប់មកអ្នកត្រូវឡើងតុលាការវិនិច្ឆ័យ។



ត្រូវការពត៌មានថែមទៀត? សូមទាក់ទងតាមខ្សែទូរស័ព្ទ SIREN's Immigrant Assistance & Information Line សំរាប់កម្មវិធីប្តូរថ្មី និងសំនួរជាទូទៅ។ ទូរស័ព្ទទាំងអស់មានបើក ពីថ្ងៃ ចន្ទ-សុក្រ ម៉ោង ១០ព្រឹក-៥ល្ងាច ហើយជាពីរភាសា អង់គ្លេសនិងភាសាដូចតទៅ : អេស្ប៉ាញ៉ុល- (408) 286-1698 វៀតណាម- (408) 286-1448 **Farsi**- (408) 286-5680 x108 និងចិន- (408) 286-5680 x109

## ចុះបើខ្ញុំពុំអាចជួលមេធាវីបាន ?

អ្នកអាចរកតំណាងការពារម្នាក់ ( the Public Defender`s Office ) ចូរសួរចៅក្រម ឲ្យនាំរកអ្នកតំណាងពីកន្លែង Public Defender។

## ចុះខ្ញុំអាចយកអ្នកបកប្រែបានទេ ?

គេគ្រប់គ្នាមានសិទ្ធិរកអ្នកបកប្រែ ឲ្យជួយនៅគ្រប់ពេលដែលលំបាក ដែលតុលាការកំពុងកាត់ក្តី។

## តើមានការអ្វីដែរ ក្នុងពេលវិនិច្ឆ័យមួយ ?

ក្នុងពេលកាត់ក្តី អ្នកចោទមានសិទ្ធិតែងតាំងស្នាក្តីម្នាក់ពីមេធាវី មកពី (PublicDefender`sOffice)។ PublicDefender គឺជាអ្នកការពារប្រជាជន ជាមេធាវីម្នាក់ដែលមុខនាទីគេជាអ្នក ការពារសិទ្ធិរបស់អ្នកជាប់ចោទ ។

បើមេធាវីតំបន់ មិនអាចមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាអ្នកជាប់ចោទបានធ្វើខុស ដោយគ្មានការសង្ស័យនោះទេ ការចោទនោះត្រូវតែលប់ចោល។

## ចុះបើសមាជិកគ្រួសារម្នាក់ជាប់ពន្ធនាគារ តើខ្ញុំត្រូវធ្វើដូចម្តេច ?

យោងទៅតាមសមាជិកគ្រួសារ ត្រូវចាប់ដោយមូលហេតុអ្វី? អ្នកប្រហែលបង់ប្រាក់ធានា ឲ្យនៅក្រៅបានរហូតដល់ថ្ងៃឡើងតុលាការ។ កន្លែងមន្ទីរបង់ប្រាក់ធានា អាចរកឃើញក្នុងសៀវភៅទូរស័ព្ទ Yellow Pages ។

## បើត្រូវជាប់ទោស តើមានប្រែប្រួលស្ថានការណ៍អន្តោប្រវេសន៍ទេ ?

សំរេចទៅលើទោសកម្ម ការជាប់ទោស អ្នកអាចប៉ះទង្គិច ដល់ភាពអន្តោប្រវេសន៍បាន ដោយមិនអាចឲ្យអ្នកសុំចូលសញ្ជាតិបាន ឬអាចឲ្យគេបញ្ជូនទៅស្រុកវិញផង។

## ដើម្បីកុំឲ្យគេចាប់ តើខ្ញុំអាចបង់ប្រាក់ទៅប៉ូលិសបានឬទេ ?

អ្នកមិនអាចជៀសវៀង ពីការចាប់ខ្លួនឬជាប់ទោស ដោយសូកលុយឲ្យទៅភ្នាក់ងារប៉ូលិសឬសូកអ្វីៗ ឬសូកភ្នាក់ងារណាដទៃទៀត ដែលធ្វើការក្នុងប្រព័ន្ធយុត្តិធម៌បានទេ។ គឺជាអំពើល្មើសច្បាប់ បើធ្វើដូច្នេះ អ្នកនឹងត្រូវជាប់ចោទ រឹតតែធ្ងន់ឡើង។

**Asian American Recovery Services (" The Place")**
1370 Tully Road,Suite 501, San Jose,CA 95122
Tel: (408) 271-3900
Toll free: 1(800) 770-5674

ភាសា : ខ្មែរ Ilocano តាកាឡុក និង វៀតណាម
ការបំរើ : មន្ទីរការពារក្មេងពីគ្រឿងញៀន និងការស្រវឹងស្រាក្នុងចំណោមកូនសិស្ស អាស៊ី នៅសាលាបឋមសិក្សា។ អន្តរាគមន៍មុនពេលសំរាប់ក្មេងអាស៊ី មានអ្នកឲ្យឱវាទ និងក្រុមជួយឲ្យយោបល់ដល់គ្រួសារ។ មានអ្នកព្យាបាលក្រោមន្ទីរពេទ្យ ដល់ក្មេងអាស៊ីជំទង់ដែលប្រើគ្រឿងញៀន។

**Correction Center for Women**
701 South Abel St., Milpitas,CA 95036
Tel : (408) 957-5414
ភាសា : អេស្ប៉ាញ៉ុល និង វៀតណាម
កិច្ចបំរើ: កន្លែងឃុំឃាំងផ្នែកស្រ្តី

**County of Santa Clara /Department of Corrections Automated Victime Notification Service**
Toll free : (800) 464-3568

ការបំរើ: អ្នកទទួលរងគ្រោះពីឧក្រិដ្ឋកម្ម អាចទូរស័ព្ទធ្វើសេចក្តីរាយការណ៍ ដោយមិនបាច់ប្រាប់ឈ្មោះ។ បន្ទាប់ពីការរាយការណ៍ទុកនឹងក្រសួងមក អ្នករងគ្រោះនឹងទទួលដំណឹង កំឡុង១៥ថ្ងៃមុនពេលគេដោះលែងអ្នកជាប់ពន្ធនាគារ ហើយបន្ទាប់មកគេនឹងប្រាប់ថែមទៀតថា អ្នកជាប់គុកនោះ ទើបនឹងបានដោះលែងហើយ។

**Crime VictimsUnited-Sacramento**
**Tel: (916) 448-3291**
ការបំរើ: សេចក្តីគាំទ្រ ការសិក្សា និង ក្រុមអនុវត្តន៍នយោបាយជួយជនដែលរងគ្រោះពីការរំលោភសិទ្ធិ។ គាំទ្រដល់អ្នកដំណាងឈរឈ្មោះ ដែលជួយទ្រទ្រង់ ដល់អ្នកដែលរងគ្រោះពីការរំលោភសិទ្ធិ។

**Elmwood Men`s Facility**
701 South Abel St.
ភាសា : អេស្ប៉ាញ៉ុល និង វៀតណាម
ការបំរើ: កន្លែងឃុំឃាំងសំរាប់បុរស

**Friends Outside**
501 Stockton Ave. San Jose, CA 95126
Tel: (408) 295-6033
ភាសា : អេស្បាញ៉ុល
ការបំរើ: ជួយដល់គ្រួសារដែលមានសមាជិកជាប់ឃុំឃាំង។ ផ្តល់ម្ហូបពេលអាសន្ន ខោអាវ និងគ្រឿងប្រើប្រាស់ក្នុងផ្ទះ។ ផ្តល់ឱវាទ ក្រុមសំរាប់ជួយ មានថ្នាក់បង្រៀនវិជ្ជាជាមាតាបិតាល្អ។ បោះជំរុំពេលវិស្សមកាល ជំនួយក្នុងពេលបុណ្យគ្រីស្មាស។ មានកិច្ចបំរើនៃមន្ទីរឃុំឃាំងផ្សេងៗ និងកម្មវិធីសំរាប់ជួយ ចំពោះការបំពុលពីប្រើថ្នាំញៀន។

**Probation Department of Santa Clara County-Palo Alto**
270 Grant Ave., Palo Alto, CA 94306
Tel : (650 ) 327- 1470

ភាសា : អេស្បាញ៉ុល និង វៀតណាម និងអ្នកបកប្រែភាសារផ្សេងម្នាក់ទៀត។
ការបំរើ: Probation Department

**Public Defender`s office**
120 Mission St., San Jose, CA 95110
Tel : (408) 299-7700
270 Grant Ave. Palo Alto, CA 94306
Tel : (650) 327-1354

ការបំរើ: តំណាងជនប្រព្រឹត្តបទល្មើសថ្នាក់មជ្ឈឹម និង ប្រព្រឹត្តបទឧក្រឹដ្ឋ ក្នុងករណីទោសមនុស្សធំនិងក្មេងជំទង់ ដែលគ្មានសមត្ថភាពជួលមេធាវិខ្លួនឯង និងជួយដំណាងអ្នកដែលមានជម្ងឺខួរក្បាលដែលមិនអាចយកជាការពិត នៅពេលឡើងតុលាការ។

**Santa Clara County Main Jail-North Jail**
150 West Hedding St., San Jose, CA 95110
Tel: (408) 299-3689

ភាសា : អេស្បាញ៉ុល និង វៀតណាម

**Volunteers in Parole**
118 W. Talor St. San Jose, CA 95110
Tel : (408) 277-1008
ភាសា : អេស្បាញ៉ុល ( មេធាវីប្រៀនប្រដៅ )
ការបំរើ: ធ្វើការជាដៃគូរជាមួយមេធាវី ដែលឲ្យឱវាទទៅអ្នកដែលបានដោះលែងមុនពេលកំណត់ ហើយបានចំណាយពេលវេលា ៤ឬ៨ម៉ោងក្នុង១ខែម្តង។ សកម្មភាពទាំងនោះ មានការជួបគ្នាជប់លៀងម្ហូបមួយឆ្នាំម្តង បំរើក្នុងការលាងឡាន ជួយរកថវិការសំរាប់ការរៀនសូត្រ ជួយចាត់ចែងក្នុងកីឡា និងកីឡាទឹក។

**Wright Center**
298 Bernal Road, San Jose, CA 95119
Tel : (408) 227-8022
ភាសា : អេស្បាញ៉ុល
ការបំរើ: កន្លែងឃុំឃាំងកែសម្រួល ឲ្យប្រសើរឡើង ដល់ក្មេងស្រីអាយុពី១២ ដល់ ១៨ឆ្នាំ ដែលកាត់ទោស ដោយតុលាការសំរាប់ក្មេងវ័យជំទង់។ សាធារណះមិនអាចទាក់ទងជាមួយបានទេ។



ត្រូវការពត៌មានថែមទៀត? សូមទាក់ទងតាមខ្សែទូរស័ព្ទ SIREN's Immigrant Assistance & Information Line សំរាប់កម្មវិធីប្តូរថ្មី និងសំនួរជាទូទៅ។ ទូរស័ព្ទទាំងអស់មានបើក ពីថ្ងៃ ចន្ទ-សុក្រ ម៉ោង ១០ព្រឹក-៥ល្ងាច ហើយជាពីរភាសា អង់គ្លេសនិងភាសាដូចតទៅ :
អេស្ប៉ាញ៉ុល- (408) 286-1698 វៀតណាម- (408) 286-1448 **Farsi**- (408) 286-5680 x108 និងចិន- (408) 286-5680 x109